N.40
31.10.02

# ក

## I- ខុទ្ទកាល័យព្រះមហាក្សត្រ

### ១_ ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ១៥-១០-២០០២ | - ព្រះរាជក្រឹត្យ នស /រកត/១០០២/២៨៥ ស្តីពីការតែងតាំងឯកឧត្តម **ចាន់ ណារ៉ា** ជាឧបការីប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា | ៣១២៥ |
| ១៥-១០-២០០២ | - ព្រះរាជក្រឹត្យ នស /រកត/១០០២/២៨៦ ស្តីពីការតែងតាំង ផ្ទេរ និងដាក់ឱ្យស្ថិតនៅក្នុងភាពទំនេរនូវចៅក្រមតុលាការខេត្ត ព្រះរាជអាជ្ញាអមតុលាការ ខេត្តមួយចំនួន | ៣១២៦ |
| ១៨-១០-២០០២ | - ព្រះរាជក្រឹត្យ នស /រកត/១០០២/២៨៩ ស្តីពីការដាក់ឯកឧត្តម **ខ្លូត រ៉ាន់ឌី** អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្មរ៉ែនិងថាមពលចូលនិវត្តន៍ | ៣១២៨ |
| ២១-១០-២០០២ | - ព្រះរាជក្រឹត្យ នស /រកត/១០០២/២៩២ ស្តីពីការផ្តល់សញ្ជាតិខ្មែរតាមសញ្ជាតូបនីយកម្មដល់លោក **ឡៅ ហ្សេរ៉ុល** ( LAU GERALD )ជនជាតិចិនសញ្ជាតិអង់គ្លេស កើតនៅក្រុងហុងកុងប្រទេសចិន | ៣១២៩ |
| ២១-១០-២០០២ | - ព្រះរាជក្រឹត្យ នស /រកត/១០០២/២៩៣ ស្តីពីការ តម្លើងឋានន្តរសក្តិថ្នាក់ឧត្តមសេនីយ៍ត្រី ជាកិច្ចបច្ឆាមរណៈចំពោះសពវរសេនីយឯក **ខាត់ ខេមរិន្ទ** | ៣១៣០ |
| ២១-១០-២០០២ | - ព្រះរាជក្រឹត្យ នស /រកត/១០០២/២៩៤ ស្តីពីការ តម្លើងឋានន្តរសក្តិថ្នាក់ឧត្តមសេនីយ៍ត្រី ជាកិច្ចបច្ឆាមរណៈចំពោះសពវរសេនីយឯក **កែវ សំអាត** | ៣១៣១ |
| ២១-១០-២០០២ | - ព្រះរាជក្រឹត្យ នស /រកត/១០០២/២៩៥ ស្តីពីការតែងតាំង ឯកឧត្តម **សូ ម៉ារ៉ា** ជាអគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ នៃក្រសួងទេសចរណ៍ | ៣១៣២ |
| ២៤-១០-២០០២ | - ព្រះរាជក្រឹត្យ នស /រកត/១០០២/២៩៧ ស្តីពីការតែងតាំងលោក **សុខ មាន** ជាឧកញ៉ា | ៣១៣៣ |
| ២៤-១០-២០០២ | - ព្រះរាជក្រឹត្យ នស /រកត/១០០២/២៩៨ ស្តីពីការ កែសំរួលថ្នាក់ក្នុងឋានន្តរសក្តិឧត្តមមន្ត្រីនៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលដែលធ្វើសមាហរណកម្មតាមព្រះរាជក្រឹត្យ នស/រកត/០៨០២/២៥១ ចុះថ្ងៃទី ២៦ ខែសីហា ឆ្នាំ ២០០២ | ៣១៣៤ |
| ២៨-១០-២០០២ | -ព្រះរាជក្រឹត្យ នស/រកត/១០០២/២៩៩ ស្តីពីការផ្តល់សញ្ជាតិខ្មែរតាមសញ្ជាតូបនីយកម្មដល់គ្រួសារលោក **គ្រីស្យង់ ហ្គោគកឺឡាំង ដេប៉ាលីយែរ** | ៣១៣៦ |
| ៣០-១០-២០០២ | - ព្រះរាជក្រឹត្យ នស /រកត/១០០២/៣០០ ស្តីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៣ | ៣១៣៧ |

## II- រាជរដ្ឋាភិបាល

### ១~ អនុក្រឹត្យ

២២-១០-២០០២ - អនុក្រឹត្យលេខ ១០៧ អនក្រ .បក ស្តីពីការតម្លើងនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុរបស់ក្រសួងទេសចរណ៍ ទៅជាអគ្គនាយកដ្ឋានរដ្ឋបាលនិងទេសចរណ៍ ៣១៣៩

២៤-១០-២០០២ - អនុក្រឹត្យលេខ ១០៨ អនក្រ .បក ស្តីពីការផ្ទេរឥណទានថវិកា ៣១៤៣

២៤-១០-២០០២ - អនុក្រឹត្យលេខ ១០៩ អនក្រ .បក ស្តីពីការបង្កើតមជ្ឈមណ្ឌលធនធានអាស៊ាន កម្ពុជា ចំណុះផ្ទាល់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ៣១៤៥

២៤-១០-២០០២ - អនុក្រឹត្យលេខ ១១០ អនក្រ .បក ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ៣១៤៧

២៩-១០-២០០២ - អនុក្រឹត្យលេខ ១១១ អនក្រ .បក ស្តីពីការផ្ទេរឥណទានថវិកា ៣១៥៣

២៤-១០-២០០២ - អនុក្រឹត្យលេខ ៥១២ អនក្រ .តត ស្តីពីការជូនមេដាយសហមេត្រី ៣១៥៥

២៤-១០-២០០២ - អនុក្រឹត្យលេខ ៥១៣ អនក្រ .តត ស្តីពីការជូនមេដាយសហមេត្រី ៣១៥៦

២៤-១០-២០០២ - អនុក្រឹត្យលេខ ៥១៤ អនក្រ .តត ស្តីពីការជូនមេដាយការងារ ៣១៥៧

២៤-១០-២០០២ - អនុក្រឹត្យលេខ ៥១៥ អនក្រ .តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៣១៥៩

២៥-១០-២០០២ - អនុក្រឹត្យលេខ ៥១៦ អនក្រ .តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៣១៦០

២៨-១០-២០០២ - អនុក្រឹត្យលេខ ៥១៧ អនក្រ .តត ស្តីពីការជូនមេដាយសហមេត្រី ៣១៦២

២៩-១០-២០០២ - អនុក្រឹត្យលេខ ៥១៨ អនក្រ .តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៣១៦៣

២៩-១០-២០០២ - អនុក្រឹត្យលេខ ៥១៩ អនក្រ .តត ស្តីពីការលុបឈ្មោះមន្ត្រីរាជការចេញពីក្របខ័ណ្ឌរដ្ឋ ៣១៦៤

២៩-១០-២០០២ - អនុក្រឹត្យលេខ ៥២០ អនក្រ .តត ស្តីពីការផ្ទេរភារកិច្ច និងតែងតាំងមន្ត្រីរាជការ ៣១៦៥

### ២~ សេចក្តីសំរេច

២១-១០-២០០២ - សេចក្តីសំរេចលេខ ៥០ សសរ ស្តីពីការបង្កើតគណៈកម្មការវាយតម្លៃ ការដេញថ្លៃក្នុងការជ្រើសរើសក្រុមហ៊ុនគ្រប់គ្រងនាវាសញ្ជាតិកម្ពុជា ៣១៦៦

## III- ការងារបណ្តាក្រសួង

### ១~ ធនាគារជាតិនៃកម្ពុជា

១៨-១០-២០០២ - ប្រកាសលេខ ធ៨-០២-២០៥ប្រក ស្តីពីការកែប្រែមណ្ឌលសិក្សាបច្ចេកទេសធនាគារ ទៅជាវិទ្យាស្ថាន បច្ចេកទេសធនាគារ ៣១៦៧

### ២~ ទីស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រមាញ់និងនេសាទ

២៨-១០-២០០២ - សេចក្តីសំរេចលេខ ៣៩៣ សសរ.កសក.បុ ស្តីពីការចាត់តាំង និងប្តូរភារកិច្ចមន្ត្រីរាជការមួយចំនួនទៅក្នុងអង្គភាពគ្រប់គ្រងគំរោង នៃគំរោងបង្កើនផលិតភាពកសិកម្មក្នុងក្របខ័ណ្ឌឥណទានធនាគារពិភពលោក និងមូលនិធិអន្តរជាតិសំរាប់ អភិវឌ្ឍន៍ កសិកម្ម ៣១៧០

# ព្រះរាជក្រឹត្យ

នស/រកត/១០០២/២៨៥

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា លេខ ៥៧៥ រស ចុះថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០០២
- យោងតាមសំណូមពរការងារចាំបាច់

## ត្រាស់បង្គាប់

មាត្រា១ .- តែងតាំងឯកឧត្តម ចាន់ ណារ៉ា ជាឧបការីប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

មាត្រា២ .- ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា៣ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

លេខ : ២១៦ ច.ល

ដើម្បីចម្លងចែក

៣៧៤-០៤-១០-០០៣០៤

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ [illegible] ឆ្នាំ២០០២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

ណាឃី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/១០០២/២៨៦

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា ដែលប្រកាសឱ្យប្រើដោយក្រឹត្យលេខ ០៦ក្រ ចុះថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ ១៩៩៣
- បានទ្រង់យល់ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០៩/នស/៩៤ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៩៤
- យោងតាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលបានការឯកភាពពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នាសម័យប្រជុំថ្ងៃទី ២៦ ខែសីហា និងថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ ២០០២

## ត្រាស់បង្គាប់

**មាត្រា១** .. I. **ត្រូវបានផ្ទេរភារកិច្ច :**

១- លោក **តាន់ សេណារ៉ុង** ចៅក្រមតុលាការខេត្តសៀមរាប ឱ្យមកបំរើការងារជាចៅក្រមនៅតុលាការក្រុងភ្នំពេញ ។

២- លោក **កែវ ឆេង** ចៅក្រមតុលាការខេត្តកំពង់ស្ពឺ ឱ្យមកបំរើការងារជាចៅក្រមនៅតុលាការខេត្តសៀមរាប ។

៣- លោក **តាន់ ឈឿន** ព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឱ្យមកបំរើការងារជា ព្រះរាជអាជ្ញាអមតុលាការខេត្តតាកែវ ។

៤- លោក **ម៉ី សុខន** ព្រះរាជអាជ្ញាអមតុលាការខេត្តតាកែវ ឱ្យមកបំរើការងារជាព្រះរាជអាជ្ញាអមតុលាការខេត្តរតនគិរី ។

៥- លោក **ដាត់ ថៃ** ព្រះរាជអាជ្ញាអមតុលាការខេត្តរតនគិរី ឱ្យមកបំរើការងារជាព្រះរាជអាជ្ញារងអមតុលាការខេត្តក្រចេះ ដោយរក្សាកាំប្រាក់នៅដដែល ។

**II.ត្រូវបានតែងតាំង :**

១- លោក **ង៉ាន់ គឹមលាន** ព្រះរាជអាជ្ញារងអមតុលាការខេត្តតាកែវ ឱ្យមកបំរើការងារជាព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។

**III.ត្រូវបានតែងតាំងជាកិច្ចនិយតកម្ម :**

១- លោក **សារ៉ាត់ ស៊ន** បច្ចុប្បន្នមានតួនាទីជាព្រះរាជអាជ្ញាអមតុលាការខេត្តមណ្ឌលគិរី ជាព្រះរាជអាជ្ញាអមតុលាការខេត្តមណ្ឌលគិរី ។

២- លោកស្រី **ឡៀម ម៉ារ៉ាន** បច្ចុប្បន្នមានតួនាទីជាអនុប្រធានតុលាការខេត្តមណ្ឌលគិរី ជាអនុប្រធានតុលាការខេត្តមណ្ឌលគិរី ។

៣- លោក **ខាំ ថងដាំ** បច្ចុប្បន្នមានតួនាទីជាអនុប្រធានតុលាការខេត្តស្ទឹងត្រែង ជាអនុប្រធានតុលាការខេត្តស្ទឹងត្រែង ។

៤- លោក **ម៉ាន់ ខាំភួន** បច្ចុប្បន្នមានតួនាទីជាព្រះរាជអាជ្ញារងអមតុលាការខេត្តស្ទឹងត្រែង ជាព្រះរាជអាជ្ញារងអមតុលាការខេត្តស្ទឹងត្រែង ។

**IV.ដាក់ឱ្យស្ថិតនៅក្នុងភាពទំនេរ :**

អនុញ្ញាតឱ្យលោកស្រី **ចែម ទេយ្យឫទ្ធិ** ចៅក្រមសាលាឧទ្ធរណ៍ ស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សរយៈពេលមួយឆ្នាំ គិតពីថ្ងៃទី ០១ ខែមិនា ឆ្នាំ ២០០៣ ដល់ថ្ងៃទី ០១ ខែមិនា ឆ្នាំ ២០០៤ ។

**មាត្រា២** .- បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៣** .- ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា៤** .- ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

លេខ :៧៧០ច.ល

៣រស-០៤.១០-០០៣០៣

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែតុលា ឆ្នាំ ២០០២

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សារី តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/១០០២/២៨៩

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** ត្រូវបានដាក់ឱ្យឯកឧត្តម **ខួត រ៉ាន់ឌី** អនុរដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ចូលនិវត្តន៍ក្នុងក្របខ័ណ្ឌរដ្ឋបាលសាធារណៈ តែនៅបន្តការងារក្នុងមុខតំណែងនយោបាយដដែល រហូតដល់មានការសំរេចជាថ្មី ។

**មាត្រា ២:** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

លេខ :៤២១០ច.ល

ដើម្បីចម្លងចែក

៣រល.០៥.១០-០០៣០៦

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០២

រាជធានីភ្នំពេញ.ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សុខ ឌាន់**

# ព្រះរាជក្រឹត្យ

នស/រកត/១០០២/២៩២

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ឡៅ ហ្សេរ៉ាល់ (LAU GERALD)** ជនជាតិចិន សញ្ជាតិអង់គ្លេស កើតថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ១៩៦៩ នៅក្រុងហុងកុង ប្រទេសចិន ។

**មាត្រា ២ :** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ. ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០២

៣រស.០៧.១០.០០៣០៩

លេខ : ២១៤ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ. ថ្ងៃទី ២៤ ខែ ១៧ ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សារី** គាន់

# ព្រះរាជក្រឹត្យ

នស/រកត/១០០២/២៩៣

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១:** តម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជាកិច្ចបច្ឆាមរណៈ ចំពោះសពលោកវរៈសេនីយ៍ឯក **ខាត់ ខេមរិន្ទ** អត្តលេខ ០២៩៥ អនុប្រធានសេនាធិការដ្ឋាន នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២:** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

លេខ : ២១៣ ច.ល

ដើម្បីចម្លងចែក

៣រល.០៧.១០.០០៣១០

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ១០ ឆ្នាំ២០០២

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ណារិន្ទ តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/១០០២/២៩៤

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១:** តម្លើងឋានន្តរសក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជាកិច្ចបច្ឆាមរណៈ ចំពោះសពលោកវរៈសេនីយ៍ឯក **កែវ សំអាត** អត្តលេខ ០២៩៩ អនុប្រធានអង្គភាពអន្តរាគមន៍ នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២:** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

ពរស.០៧.១០.០០៣១១

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០២

លេខ : ២១២ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ ១១ ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

# ព្រះរាជក្រឹត្យ

នស/រកត/១០០២/៧៩៥

## យើង

## ព្រះបាទសម្ដេចព្រះ នរោត្ដម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្ដម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងទេសចរណ៍
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយ របស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១.** តែងតាំងឯកឧត្ដម **សូ ម៉ារ៉ា** ជាអគ្គនាយក នៃអគ្គនាយកដ្ឋាន រដ្ឋបាល និងហិរញ្ញវត្ថុ នៃក្រសួងទេសចរណ៍ ។

**មាត្រា ២ :** រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ :** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ដលេខានេះតទៅ ៕

**ព្រះហស្ដលេខា និង ព្រះរាជលញ្ឆករ**

**នរោត្ដម សីហនុ**

លេខ : ២១១ ច.ល

ដើម្បីចម្លងចែក

៣ក.ស-០៧.១០.០០៣១៧

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ត៧ ឆ្នាំ២០០២

ផ្ញើទៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាង ភាន់**

# ព្រះរាជក្រឹត្យ

នស/រកត/១០០២/២៩៧

**យើង**

**ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

---

**តែងតាំង**

**លោក សុខ មាន**

**ជា**

**ឧកញ៉ា**

**ព្រះហស្ថលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

លេខ:២១៥ ច.ល

ដើម្បីចម្លងចែក

៣រល.០២.១០.០០៣១៤

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ [illegible] ឆ្នាំ២០០២

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០២* អគ្គលេខាធិការរាជរដ្ឋាភិបាល

សារិ៍ តាន់

# ព្រះរាជក្រឹត្យ

នស/រកត/១០០២/២៩៨

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨០២/២៥១ ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០២ ស្តីពីការធ្វើសមាហរណកម្មទៅក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** ត្រូវបានកែសំរួលថ្នាក់ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ដែលបានធ្វើសមាហរណកម្ម តាមព្រះរាជក្រឹត្យលេខ នស/រកត/០៨០២/២៥១ ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០២ ស្តីពីការធ្វើសមាហរណកម្ម ទៅក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នូវមន្ត្រីរាជការស៊ីវិលដូចមានរាយនាមខាងក្រោម :

១- ឯកឧត្តម **ចិន ឈិន** ពីឧត្តមមន្ត្រីថ្នាក់លេខ ២ ទៅជាឧត្តមមន្ត្រីថ្នាក់លេខ ១

២- ឯកឧត្តម **លឹម គានហោ** ពីឧត្តមមន្ត្រីថ្នាក់លេខ ៤ ទៅជាឧត្តមមន្ត្រីថ្នាក់លេខ ១

៣- ឯកឧត្តម **សួន សិទ្ធី** ពីឧត្តមមន្ត្រីថ្នាក់លេខ ៥ ទៅជាឧត្តមមន្ត្រីថ្នាក់លេខ ៣

៤- ឯកឧត្តម **នូ សាំងខន** ពីឧត្តមមន្ត្រីថ្នាក់លេខ ៤ ទៅជាឧត្តមមន្ត្រីថ្នាក់លេខ ៣

៥- ឯកឧត្តម **លី ធុជ** ពីឧត្តមមន្ត្រីថ្នាក់លេខ ៦ ទៅជាឧត្តមមន្ត្រីថ្នាក់លេខ ៥

៦- ឯកឧត្តម **មួង សៅខន** ពីឧត្តមមន្ត្រីថ្នាក់លេខ ១ ទៅជាឧត្តមមន្ត្រីថ្នាក់លេខ ៤

**មាត្រា ២** : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣** : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

លេខ : ៤១៧ ច.ល

ដើម្បីចម្លងចែក

៣រល.០៤.១០-០០៣១៥

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ១៣ ឆ្នាំ២០០២

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០២*

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សាខឹ តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/១០០២/២៩៤

**យើង**

**ព្រះបាទសម្ដេចព្រះ នរោត្ដម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្ដម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីសញ្ជាតិ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ :** ផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់គ្រួសារលោក **គ្រីស្ទង់ ហ្គោកឺឡាំង ដេប៉ាលីយែរ** ដែលមានសមាជិក ដូចរាយនាមខាងក្រោម :

១- លោក **គ្រីស្ទង់ ហ្គោកឺឡាំង ដេប៉ាលីយែរ** ( **Christian GAUQUELIN des PALLIERES** ) សញ្ជាតិដើមបារាំង កើតថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ១៩៣៤ នៅប្រទេសបារាំង (ជាស្វាមី ) ។

២- អ្នកស្រី **ប៊ូសា ម៉ារីហ្វ្រង់** ( **Bouchard Marie France** ) សញ្ជាតិដើមបារាំង កើតថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ១៩៤២ នៅប្រទេសបារាំង (ជាភរិយា) ។

**មាត្រា ២ :** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ដលេខានេះតទៅ ៕

**ព្រះហស្ដលេខា និង ព្រះរាជលញ្ឆករ**

**នរោត្ដម សីហនុ**

៣៩៧.០៧.១០.០០៣៦

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០២*

លេខ : ២១៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ [illegible] ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ណារ៉ុ តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/១០០២/៣០០

**យើង**

**ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

-បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណបក្សនយោបាយ

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០១៩៨/០៤២ ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី ២

-បានទ្រង់យល់លិខិតលេខ ៩៣៥ រស របស់រដ្ឋសភា ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០២ ស្តីពីលទ្ធផលនៃការបោះឆ្នោត សម្តែងការយល់ព្រមលើ សមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះ ឆ្នោត

-បានទ្រង់យល់សំណើរបស់សម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៣ ដែលមានសមាសភាពដូចតទៅនេះ :

១- ឯកឧត្តម អ៊ឹម សួស្តី ប្រធាន
២- ឯកឧត្តម ថៃ នាយលាង អនុប្រធាន
៣- ឯកឧត្តម មាន សាវិ សមាជិក
៤- លោកជំទាវ កុយ ទេត សមាជិកា
៥- លោកជំទាវ ស៊ីន ជុំបូ សមាជិកា

**មាត្រា ២** : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និងឯកឧត្តម លោកជំទាវ ដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុក អនុវត្តព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពី ថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែតុលា ឆ្នាំ ២០០២

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

នស/រកត-១០០២-៣១៧ **នរោត្តម សីហនុ**

បានក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ : ៧១៩ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សោម ឌី តាន់**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១០៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតម្លើងនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ របស់ក្រសួងទេសចរណ៍ ទៅជា អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ/បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ/បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ/បក ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០០ ស្តីពីការកែសំរួលមុខងារ និងភារៈកិច្ច និងការបង្កើតក្រុមអ្នកច្បាប់ និង នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាន របស់ក្រសួង-ទេសចរណ៍
- យោងតាមសំណូមពរចាំបាច់នៃការងារ

# ស ម្រេ ច

**មាត្រា ១ .-**

ត្រូវបានតម្លើងនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុរបស់ក្រសួងទេសចរណ៍ ទៅជាអគ្គនាយកដ្ឋាន រដ្ឋបាល និងហិរញ្ញវត្ថុ ។

**មាត្រា ២ .-**

អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ទទួលបន្ទុក : គ្រប់គ្រងការងាររដ្ឋបាល បូកសរុបរបាយការណ៍ ឯកសារ បុគ្គលិក ផែនការ ហិរញ្ញវត្ថុ សំភារៈបរិក្ខារ សារពើភ័ណ្ឌ ការងារបណ្តុះបណ្តាល ក្របខ័ណ្ឌក្រសួង ការងារសិក្សាស្រាវជ្រាវ និងសុពលភាពការងារ សំរបសំរួលរាល់សកម្មភាពរដ្ឋបាល នៅក្នុងក្រសួងជាមួយបណ្តា អង្គភាពមូលដ្ឋានខេត្ត-ក្រុង និងជាមួយបណ្តាក្រសួងនានា ។

អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ដឹកនាំដោយអគ្គនាយក ០១រូប និងអមដោយ អគ្គនាយករង ជាជំនួយការតាមការចាំបាច់ ។

អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុរបស់ក្រសួងទេសចរណ៍ មាននាយកដ្ឋានចំណុះ ចំនួន ០៣ ÷

១- នាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ

២- នាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស

៣- នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ ។

**មាត្រា ៣ .-**

នាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ មានភារៈកិច្ច ÷

- សំរបសំរួលកិច្ចការរបស់ក្រសួងនៅថ្នាក់កណ្តាល និងរវាងថ្នាក់កណ្តាលជាមួយនឹងអង្គភាពមូលដ្ឋាន ក្រោមចំណុះ
- គ្រប់គ្រង និងចរាចរឯកសាររដ្ឋបាលផ្សេងៗរបស់ក្រសួងទេសចរណ៍
- គ្រប់គ្រងការងារទំនាក់ទំនងអន្តរក្រសួង និងទំនាក់ទំនងសាធារណៈ
- សរុប និងធ្វើរបាយការណ៍ការងារ និងសកម្មភាពផ្សេងៗរបស់ក្រសួង ។

នាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ ដឹកនាំដោយប្រធាននាយកដ្ឋាន ០១ រូប និងអមដោយ អនុប្រធាននាយកដ្ឋានជាជំនួយការ តាមការចាំបាច់ ។

**មាត្រា ៤ .–**

នាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស មានភារកិច្ច ÷

- គ្រប់គ្រងផ្នែករដ្ឋបាល មន្ត្រីរាជការរបស់ក្រសួង ដោយទំនាក់ទំនងជាមួយរដ្ឋលេខាធិការដ្ឋាន-មុខងារសាធារណៈ
- រៀបចំរាល់លិខិតរដ្ឋបាលសំរាប់ការគ្រប់គ្រងអាជីព
- ធ្វើកម្មវិធីតំណែងឯកទេស និងធនធានមនុស្សរបស់ក្រសួង
- វាយតំលៃតំរូវការក្នុងការបណ្តុះបណ្តាលបុគ្គលិក
- រៀបចំនយោបាយបណ្តុះបណ្តាលដំបូង និងបន្ត ដោយសហការជាមួយនាយកដ្ឋានជំនាញ និងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងអនុវត្តនយោបាយនោះ
- រៀបចំស្ថិតិលើការគ្រប់គ្រងបុគ្គលិក និងតារាងពតិមានប្រតិបត្តិ
- គ្រប់គ្រងការងារសង្គមរបស់ក្រសួង
- ទទួលកិច្ចការលើកសរសើរ និងជូនរង្វាន់ ។

នាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស ដឹកនាំដោយប្រធាននាយកដ្ឋាន ០១ រូប និងអមដោយអនុប្រធាននាយកដ្ឋានជាជំនួយការ តាមការចាំបាច់ ។

**មាត្រា ៥ .–**

នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ មានភារកិច្ច ÷

- លើកគំរោងថវិកាក្រសួង និងតាមដានវិលកពីការប្រតិបត្តិ
- ប្រមូលចំណូលអោយបានសមស្របតាមច្បាប់ហិរញ្ញវត្ថុ
- ប្រមូលផ្តុំ និងសំរបសំរួលជំពូកថវិកា
- តាមដានវិលកការគ្រប់គ្រងគណនីពិសេស
- ប្រមូលផ្តុំ និងសំរបសំរួលរាល់ចំណាយរបស់ក្រសួង
- គ្រប់គ្រងបន្ទុកគណនីរបស់ការអនុវត្តន៍លទ្ធកម្មសាធារណៈ
- ប្រមូលផ្តុំតំរូវការធ្វើកម្មវិធីចំណាយ គ្រប់គ្រងការរៀបចំជួសជុលសំភារៈ និងធ្វើបញ្ជីសារពើភ័ណ្ឌ
- ធ្វើកម្មវិធីចំណាយបែងចែកប្រេងឥន្ធនៈ និងគ្រឿងបន្លាស់
- កាន់បញ្ជីជាប្រចាំ នូវសាលាកប័ត្រ និងគណនេយ្យរូបធាតុ

- សកម្មភាពខាងហិរញ្ញវត្ថុ និងបន្ទុកគណនី
- ត្រួតពិនិត្យបច្ចេកទេស នៃការប្រតិបត្តិលទ្ធកម្មសាធារណៈ ។

នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ ដឹកនាំដោយប្រធាននាយកដ្ឋាន ០១ រូប និងអមដោយអនុប្រធាននាយកដ្ឋានជាជំនួយការ តាមការចាំបាច់ ។

**មាត្រា ៦ .–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៧ .–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ។

**មាត្រា ៨ .–**

អនុក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ តុលា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**<u>កន្លែងទទួល</u>**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចប្រការ ៧

-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១០៩ អនុក្រ.បក

# អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ , ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ១១/នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០១/១៥ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យ លេខ ០៣ អនក្រ.បក , ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្តីពីការបែងចែកឥណទានថវិកាចំណាយ តាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យ លេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្តីពីការផ្ទេរឥណទានថវិកា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ២.៩៨០ លានរៀល ( ពីរពាន់ប្រាំបួនរយប៉ែតសិបលានរៀល ) ពីជំពូក ៤០ (ចំណាយផ្សេងៗ ) សង VAT មកជំពូក ១១ ( ចំណាយដំណើរការរដ្ឋបាល សំភារៈ និងការផ្គត់ផ្គង់តូច ) របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ចំណាយដំណើរការរដ្ឋបាល ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២៤ ខែ ១៧ ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

**បានយកសេចក្តីជំរាបជូន**

**សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ១០៩ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការបង្កើតមជ្ឈមណ្ឌលធនធានអាស៊ានកម្ពុជា
## ចំណុះផ្ទាល់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញ អនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានឃើញ អនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០២ ស្តីពីការបង្កើតគណៈកម្មាធិការជាតិទាំង ៦ សំរាប់កិច្ចសហប្រតិបត្តិការអាស៊ានផ្នែកជំនាញ
- តាមសំណើរបស់រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

## សំរេច

**មាត្រា ១ .-**

បង្កើតមជ្ឈមណ្ឌលធនធានអាស៊ានកម្ពុជា ហៅកាត់ថា ម.ធ.អ.ក. ចំណុះផ្ទាល់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ មានឋានៈស្មើនាយកដ្ឋាន ។

**មាត្រា ២ .-**

មជ្ឈមណ្ឌលធនធានអាស៊ានកម្ពុជា មានមុខងារ និងភារកិច្ចដូចខាងក្រោម ÷

- ផ្លាស់ប្តូរ និងផ្សព្វផ្សាយពត៌មាន អំពីវិស័យមុខងារសាធារណៈជាមួយបណ្តាមជ្ឈមណ្ឌលធនធានអាស៊ាន នៃប្រទេសសមាជិកអាស៊ាន

- គ្រប់គ្រងពតិមាន និងឯកសារដែលទាក់ទងនឹងវិស័យមុខងារសាធារណៈអាស៊ាន
- រៀបចំឯកសារ និងស្នើសុំយោបល់សំរេចពីគណៈកម្មាធិការជាតិ សំរាប់កិច្ចសហប្រតិបត្តិការអាស៊ាន ផ្នែកមុខងារសាធារណៈ ក្នុងក្របខ័ណ្ឌនៃទំនាក់ទំនងអាស៊ាន មានជាអាទិ ផែនការបណ្តុះបណ្តាលបង្កើនសមត្ថភាពមន្ត្រីរាជការស៊ីវិល ការចូលរួមប្រជុំ និងសកម្មភាពជំនាញផ្នែកមុខងារសាធារណៈ
- សហការជាមួយលេខាធិការដ្ឋានជាតិអាស៊ានកម្ពុជា អំពីកិច្ចប្រតិបត្តិការអាស៊ាន លើវិស័យមុខងារសាធារណៈ
- លើកគំរោងផែនការចំណាយសំរាប់សកម្មភាពរបស់មជ្ឈមណ្ឌលធនធានអាស៊ានកម្ពុជា
- ធ្វើរបាយការណ៍ អំពីសកម្មភាពការងារជូនថ្នាក់ដឹកនាំនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គណៈកម្មាធិការជាតិ សំរាប់កិច្ចសហប្រតិបត្តិការអាស៊ាន ផ្នែកមុខងារសាធារណៈ និងលេខាធិការដ្ឋានជាតិអាស៊ានកម្ពុជា ។

**មាត្រា ៣ .-**

មជ្ឈមណ្ឌលធនធានអាស៊ានកម្ពុជា ដឹកនាំដោយប្រធាន ១រូប និងមានអនុប្រធានជាជំនួយការតាមការចាំបាច់ ។

**មាត្រា ៤ .-**

ការរៀបចំ និងការប្រព្រឹត្តទៅ នៃមជ្ឈមណ្ឌលធនធានអាស៊ានកម្ពុជា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

**មាត្រា ៥ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ១០ ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រីសូមចុះហត្ថលេខា

**រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ**

**ពេជ្រ ប៊ុនធិន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ១១០.....អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅរបស់ អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី

❖❖❖❖❖

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលបានប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/ រកម/០៩៩៩/ ១០ ចុះថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកិច្ចការនារី និងអតីតយុទ្ធជន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០១/០៣៦ ចុះថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ ២០០១ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០១/២០១ ចុះថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ២០០១ ស្តីពីការតែងតាំង អគ្គលេខាធិការនៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី
- យោងតាមសំណើរបស់ប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.** –

អនុក្រឹត្យនេះកំណត់ភារកិច្ច និងការរៀបចំផ្នែកនានា របស់អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ដែលហៅកាត់ថា " **ក.ជ.ក.ស** " ។

## ជំពូកទី ២

## តួនាទី និង ភារកិច្ច

**មាត្រា ២.** –

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី មានអគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយជាអង្គភាពប្រតិបត្តិ ដែលត្រូវបានដឹកនាំ និង គ្រប់គ្រងដោយ អគ្គលេខាធិការមួយរូប និង អគ្គលេខាធិការរងពីររូប ។

**មាត្រា ៣.** –

អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី មានបេសកកម្មដាក់អោយដំណើរការនូវការងារតាមការណែនាំ និងការចង្អុលទិសរបស់ប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ។

**មាត្រា ៤.** –

អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ជាសេនាធិការ របស់ **ក.ជ.ក.ស** ក្នុងការ :

១-អនុវត្តការងារប្រចាំថ្ងៃរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី និង របស់អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ រួមមាន:

- ការងារគ្រប់គ្រងមន្ត្រី បុគ្គលិកនៃអគ្គលេខាធិការដ្ឋាន
- ការគ្រប់គ្រងថវិកា និង ទ្រព្យសម្បត្តិ ដទៃទៀតរបស់ក្រុមប្រឹក្សា ដោយអនុលោមតាមការសំរេចរបស់ **ក.ជ.ក.ស**
- រៀបចំការប្រជុំសាមញ្ញ និងវិសាមញ្ញទាំងអស់ រួមទាំងការធ្វើកំណត់ហេតុ និងរបាយការណ៍ អំពីសកម្មភាពរបស់ **ក.ជ.ក.ស**

២-រៀបចំផែនការសកម្មភាពការងារ រយៈពេលខ្លី មធ្យម វែង របស់ **ក.ជ.ក.ស**

៣-រៀបចំរបាយការណ៍ជាតិស្តីពីការអនុវត្តន៍អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ (CEDAW) ជូន **ក.ជ.ក.ស** ដើម្បីពិនិត្យនិងកែលំអដាក់ជូនរាជរដ្ឋាភិបាលសំរេច និង ផ្ញើជូនអគ្គលេខាធិការ អង្គការសហប្រជាជាតិ

៤-ពិនិត្យតាមដានស្ថានភាពរបស់ស្ត្រីនៅកម្ពុជា ដោយផ្អែកលើគោលនយោបាយរបស់រាជរដ្ឋាភិបាល និងគោលដៅសន្និសីទកំពូលសកលលោកដើម្បីស្ត្រី

៥- ធ្វើសហប្រតិបត្តិការ និងសហការសំរបសំរួលជាមួយក្រសួងនានា អង្គការជាតិ និងអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ដើម្បីអោយការងារ **ក.ជ.ក.ស** មានប្រសិទ្ធភាពខ្ពស់

៦- រៀបចំបណ្ណាល័យសំរាប់តំកល់ព័ត៌មាន និងឯកសារទាំងអស់ដែលពាក់ពន្ធ័ទៅនឹងស្ត្រី រួមមានឯកសារជាផ្លូវការ ឯកសារសំរាប់ការសិក្សាស្រាវជ្រាវ របាយការណ៍ ផែនការសកម្មភាព ។

**មាត្រា ៥. –**

១- ថវិការបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រីរួមមាន :

ក- ថវិការដ្ឋ ដែលជាឧបសម្ព័ន្ធ នៃថវិការបស់ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ។

ខ- ជំនួយឧបត្ថម្ភពីអង្គការអន្តរជាតិ ប្រទេសផ្តល់អំណោយ សប្បុរសជន ជាតិ ឬ បរទេស ។

២- ប្រភពចំណូលទាំងអស់របស់ក្រុមប្រឹក្សា ក្រៅពីថវិការដ្ឋ ត្រូវបញ្ចូលក្នុងគណនី របស់ក្រុមប្រឹក្សា នៅក្នុងធនាគារអនុម័តដោយក្រុមប្រឹក្សា ដែលរដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ជាអាណាប័ក និងអគ្គលេខាធិការ នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ជាអាណាប័កផ្ទេរសិទ្ធ ។ ការប្រើប្រាស់ថវិកាក្រៅពីភារកិច្ច ដំណើរការប្រចាំថ្ងៃ ត្រូវមានការអនុញ្ញាតពីក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី

៣-ការគ្រប់គ្រងថវិកា និងធនធានសម្ភារៈបរិក្ខារ របស់ក្រុមប្រឹក្សាត្រូវអនុវត្តតាមគោលការណ៍ ហិរញ្ញវត្ថុនៃ រាជរដ្ឋាភិបាល និងយោងតាមសំណូមពររបស់អ្នកផ្តល់ជំនួយ ។

៤-គណនី របស់ក្រុមប្រឹក្សា ក្រៅពីថវិការដ្ឋ ត្រូវត្រួតពិនិត្យដោយសវនករមួយក្រុម ដែលចាត់តាំងដោយក្រុមប្រឹក្សា និងតាមសំណូមពររបស់អ្នកផ្តល់ជំនួយ ។

៥- សេចក្តីរាយការណ៍ស្តីពីតុល្យភាព នៃការចំណូលចំណាយថវិកាសម្ភារៈ របស់ក្រុមប្រឹក្សាត្រូវរៀបចំឡើង និងដាក់ជូនសមាជិកា-សមាជិក ទាំងអស់របស់ក្រុមប្រឹក្សាដើម្បីពិនិត្យ និង ជ្រាបជាព័ត៌មាន ក្នុងរយៈពេលមិនហួសពីបីខែ បន្ទាប់ពីការជំរះបញ្ជីប្រចាំឆ្នាំនីមួយៗ ។

៦- ក្នុងករណីដែល **ក.ជ.ក.ស** មិនដំណើរការ ឬ ចប់បេសកកម្ម ចំនួលក្រៅពីថវិការដ្ឋ ត្រូវផ្ទេរទៅក្រុមប្រឹក្សាណា ដែលមានបេសកកម្មប្រហាក់ប្រហែល តាមការសំរេចរបស់រាជរដ្ឋាភិបាល ។

# ជំពូកទី ៣
# រចនាសម្ព័ន្ធ

**មាត្រា ៦.-**

អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃ **គ.ជ.ក.ស** មានរចនាសម្ព័ន្ធដូចតទៅ ៈ

**១-ផ្នែកបូកសរុប និង ហិរញ្ញកិច្ច**

មានតួនាទីជួយដល់អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ ក្នុងការអនុវត្តនីការងាររដ្ឋបាលប្រចាំថ្ងៃ និង ការងារហិរញ្ញកិច្ច ដោយមានភារកិច្ចដូចតទៅ ៈ

- ចុះបញ្ជីរាល់លិខិតចេញ-ចូល ធ្វើលិខិតផ្សេងៗ បញ្ជូនលិខិត និង ទំនាក់ទំនងជាមួយសាធារណជន
- រៀបចំ និង អនុវត្ត នូវទំរង់បែបបទគ្រប់គ្រង មន្ត្រី បុគ្គលិក ដោយគោរព និង អនុវត្តច្បាប់ វិន័យ និង បទបញ្ជាផ្ទៃក្នុងរបស់ **គ.ជ.ក.ស**
- រៀបចំសាលប្រជុំធ្វើពិធីការ ធ្វើកំណត់ហេតុ របាយការណ៍ពីអង្គប្រជុំ របស់ **គ.ជ.ក.ស** និង អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍
- ធ្វើរបាយការណ៍បូកសរុបការងាររបស់អគ្គលេខាធិការដ្ឋាន និងរបស់ **គ.ជ.ក.ស** រាល់ត្រីមាសនិងឆ្នាំ រៀបចំបណ្ណាល័យ ថែរក្សារាល់ឯកសារទ្រព្យសម្បត្តិរបស់ **គ.ជ.ក.ស**
- រៀបចំ និងធ្វើគំរោងថវិកាប្រចាំឆ្នាំ និងគំរោងផ្សេងៗ ទៀតរបស់ **គ.ជ.ក.ស**
- ធ្វើរបាយការណ៍ អំពីសកម្មភាពផ្នែករបស់ខ្លួន ជូនអគ្គលេខាធិការដ្ឋាន ។

**២- អនុគណៈកម្មការជំនាញ**

អនុគណៈកម្មការជំនាញមានចំនួន ២ សំរាប់អនុវត្តភារកិច្ច ដូចដែលមានចែងក្នុងមាត្រា៤ នៃ ព្រះរាជក្រឹត្យ ស្តីពីការ បង្កើត **គ.ជ.ក.ស** ។

អនុគណៈកម្មការជំនាញមានតួនាទីជាជំនួយការអគ្គលេខាធិការដ្ឋានលើការងារសំរបសំរួល តាមដាន ត្រួតពិនិត្យវាយតំលៃ ផ្តល់យោបល់ ផ្តល់អនុសាសន៍ និងជំរុញការអនុវត្តនីគោលនយោបាយជាតិ ច្បាប់ជាតិ ការអនុវត្តនី កិច្ចព្រមព្រៀងច្បាប់អន្តរជាតិនានាដែលពាក់ព័ន្ធនឹងសិទ្ធិនារី និង វិធានការដែលទាក់ទងដល់ការលើកកំពស់ស្ថានភាព តួនាទី និង សុខុមាលភាព សង្គមស្ត្រីកម្ពុជា ។

អនុគណៈកម្មការជំនាញនីមួយៗមានភារកិច្ចដូចតទៅ ៈ

**ក - អនុគណៈកម្មការជំនាញផ្នែកសំរបសំរួល ជំរុញការអនុវត្តន៍គោលនយោបាយ ច្បាប់ជាតិ បទបញ្ជា និងវិធានការដែលពាក់ព័ន្ធនឹងស្ត្រី**

- សិក្សា និងជំរុញការអនុវត្តន៍គោលនយោបាយជាតិ
- សិក្សាស្រាវជ្រាវអំពីច្បាប់ជាតិ បទបញ្ជា និងវិធានការ
- សំរបសំរួល សហប្រតិបត្តិការជាមួយបណ្តាក្រសួង អង្គការជាតិ-អន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ក្រុមឯកទេស នានា និងក្រុមប្រឹក្សាជាតិនៃប្រទេសដទៃទៀត
- ផ្សព្វផ្សាយតាមរយៈ ប្រព័ន្ធផ្សព្វផ្សាយលើគ្រប់រូបភាព
- ចងក្រង និងផលិតឯកសារផ្សេងៗ

**ខ - អនុគណៈកម្មការជំនាញ ផ្នែកតាមដានការអនុវត្តន៍កិច្ចព្រមព្រៀងច្បាប់អន្តរជាតិ ពាក់ព័ន្ធសិទ្ធិនារី និងរៀបចំរបាយការណ៍អនុសញ្ញា ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ ( CEDAW )**

- ពិនិត្យរៀបចំរបាយការណ៍ CEDAW ផ្តល់យោបល់លើការអនុវត្តន៍ ដោយធ្វើជាអនុសាសន៍ ដាក់ជូន **ក.ជ.ក.ស** ដើម្បីពិនិត្យសំរេច និងធ្វើជូនរាជរដ្ឋាភិបាល
- សិក្សាស្រាវជ្រាវ ពីអនុសញ្ញាអន្តរជាតិ នានា ដែលពាក់ព័ន្ធនឹងសិទ្ធិនារី និងចងក្រងឯកសារដើម្បីផ្សព្វផ្សាយ
- ពិនិត្យតាមដានការបញ្ជ្រាបយេនឌ័រ ដល់មន្ត្រីរាជការ ថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ ។

**មាត្រា ៧. –**

- អនុគណៈកម្មការជំនាញនីមួយៗ ត្រូវដឹកនាំដោយអគ្គលេខាធិការរងនៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី
- ប្រធានផ្នែកបូកសរុប និងហិរញ្ញកិច្ច និងសមាជិកា-សមាជិក របស់អនុគណៈកម្មការជំនាញត្រូវជ្រើសរើសដោយប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ក្នុងចំណោមមន្ត្រីរាជការទាំងពីរភេទ ដែលមានក្របខ័ណ្ឌស្រាប់

អង្គការលេខនៃរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃ **ក.ជ.ក.ស** មានដូចក្នុងឧបសម្ព័ន្ធភ្ជាប់និង អនុក្រឹត្យនេះ ។

# ជំពូកទី ៤

# អវសានប្បញ្ញត្តិ

**មាត្រា ៨. –**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹង អនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៩. –**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងអតីតយុទ្ធជន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ព្រមទាំងសមាជិក សមាជិកា ទាំងអស់នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញថ្ងៃទី ២៤ ខែ តុលា ឆ្នាំ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រីសូមចុះហត្ថលេខា

រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងអតីតយុទ្ធជន និងជា

ប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី

**មូ សុខហួរ**

**<u>កន្លែងទទួល</u> :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា

- អគ្គលេខាធិការដ្ឋាន រដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

- ដូចមាត្រា៩

- ឯកសារ-កាលប្បវត្តិ



4

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១១១ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ , ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១/នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០១/១៥ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក , ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្តីពីការបែងចែកឥណទានថវិកាចំណាយតាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក,ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្តីពីការផ្ទេរឥណទានថវិកា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ៦.០០០ លានរៀល ( ប្រាំមួយពាន់លានរៀលគត់ ) ពី ជំពូក ៤០ ( ចំណាយផ្សេងៗ ) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ៣១ ( អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ ) របស់ក្រសួងមហាផ្ទៃ ផ្នែករដ្ឋបាលទូទៅ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០២ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើង ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ទូទាត់បំណុលថ្លៃផលិតអត្តសញ្ញាណប័ណ្ណ សញ្ជាតិខ្មែរ សងអោយក្រុមហ៊ុន ឈុន ហុង ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

## ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥១២ អនក្រ.តត

# អនុក្រឹត្យ
## ស្ដីពីការជូនមេដាយសហមេត្រី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

### សំរេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **អស្សឫទ្ធិ** ជូនលោកវរសេនីយ៍ឯក Vankam XAIMOUNTY អនុព័ន្ធយោធានៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលបានមកបំពេញភារកិច្ចសំរេចបានលទ្ធផលល្អប្រសើរ ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ និងអគ្គមេបញ្ជាការ កងយោធពលខេមរភូមិន្ទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ ១០ ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥១៧. អនក្រ. បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី

&&&&&

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកព/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

## សំរេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **អស្សឫទ្ធិ** ជូនមន្ត្រីតំណាងសហភាពអឺរ៉ុប ដែលបានជួយរៀបចំទុកដាក់ឯកសារនិងស្តុកទុកអាវុធជាតិផ្ទុះ ប្រកបដោយសុវត្ថិភាពខ្ពស់ ដូចមានខាងក្រោម ÷

១-ក្រុមការងារសហភាពអឺរ៉ុប ( EU/ASAC )

២-លោក DAVID DE BEER នាយកគំរោងសហភាពអឺរ៉ុប ( EU/ASAC )

៣-លោក ALAIN PERIGAUD នាយករងគំរោងសហភាពអឺរ៉ុប ( EU/ASAC )

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ និងអគ្គមេបញ្ជាការ កងយោធពលខេមរភូមិន្ទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥០៤ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

## <u>ស ំ រ េ ច</u>

**មាត្រា១** : ត្រូវបានបំពាក់ **មេដាយការងារ** ជូននាយទាហាន ចំនួន ១១រូប ដែលមានស្នាដៃល្អ ចូលរួមសហការជាមួយក្រុមការងារសហភាពអឺរ៉ុប (EU/ASAC) ក្នុងការរៀបចំទុកដាក់ឯកសារនិងស្តុកទុកអាវុធជាតិផ្ទុះ ទទួលបានលទ្ធផលល្អប្រសើរនិងសុវត្ថិភាពខ្ពស់ ដូចមានរាយនាមខាងក្រោម ÷

**ក – <u>មេដាយមាសចំនួន០៤រូប</u>**

១-ឧត្តមសេនីយ៍ឯក ជា សារ៉ែន អត្តលេខ ០០០០៩០ មេបញ្ជាការរង កងទ័ពជើងគោក

២-ឧត្តមសេនីយ៍ទោ ឡៅ សុទ្ធ អត្តលេខ ០០០២២៩ អគ្គនាយករង អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស

៣-ឧត្តមសេនីយ៍ត្រី ស្វួន គីមស៊ីន អត្តលេខ ០០០៤៩៦ នាយក នាយកដ្ឋានបំពាក់សំភារៈសឹក

៤-ឧត្តមសេនីយ៍ត្រី យ៉ាវ៉ល់ ពិសិដ្ឋ អត្តលេខ ០០០៣២៨ នាយក ទីចាត់ការបច្ចេកទេស អគ្គបញ្ជាការដ្ឋាន

**ខ – <u>មេដាយប្រាក់ចំនួន០២រូប</u>**

១-វរសេនីយ៍ឯក ម៉ឺន យន់ អត្តលេខ ០០១២១៤ នាយករង នាយកដ្ឋានបំពាក់សំភារៈសឹក

២-វរសេនីយ៍ត្រី ឃួន សីណារ៉ា អត្តលេខ ០១០៦២១ នាយរងការិយាល័យទី៤ យោធភូមិភាគទី ៥

**គ – <u>មេដាយសំរឹទ្ធចំនួន០៥រូប</u>**

១-អនុសេនីយ៍ទោ កែវ ភូមិន្ទ អត្តលេខ ០២១៦៧២ ជំនួយការឯកទេស-បច្ចេកទេស យោធភូមិភាគទី៥

២-អនុសេនីយ៍ទោ ដាន់ សារុទ្ធី អត្តលេខ ០១៥៨០៣ នាយផ្នែកសព្វាវុធការិយាល័យទី៤ យោធភូមិភាគទី៥

៣-អនុសេនីយ៍ត្រី ជួន ចណ្ណារ៉ា អត្តលេខ ០៣០២១០ ជំនួយការផ្នែកសព្វាវុធការិយាល័យទី៤ យោធភូមិភាគទី៥

៤-អនុសេនីយ៍ត្រី **នួច សំអួន** អត្តលេខ ០៣៦៧៦៤ ជំនួយការឯកទេស-បច្ចេកទេស យោធភូមិភាគទី៥

៥-នាយចំណង់ **ស៊ឹម សារឿន** អត្តលេខ ០៥១៩២៧ ជំនួយការកុំព្យូទ័រឯកទេស-បច្ចេកទេស យោធភូមិភាគទី៥

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ និងអគ្គមេបញ្ជាការ កងយោធពលខេមរភូមិន្ទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៨ ខែ ១០ ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥១៥ អនក្រ.តត

## អនុក្រឹត្យ

### ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យ លេខ ៨៧ អនក្រ.បក. ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា

### សំរេច

**មាត្រា ១ :** តែងតាំងលោក **ហ៊ូ ទុន្សី** ជាអគ្គនាយករងនៃអគ្គនាយកដ្ឋានការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលអនុវត្តអនុក្រឹត្យនេះឱ្យបានសំរេច ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចម្លងជូន**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ២
-ឯកសារ-កាលប្បវត្តិ

P.5

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ៥១៦ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

*******

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## សំរេច

**មាត្រា ១** : ត្រូវបានតែងតាំងមន្ត្រីរាជការនៃក្រសួងយុត្តិធម៌ ដូចមានរាយនាមខាងក្រោម ៖

១- លោក **កែវ សុផល** ជាអធិការ ទទួលបន្ទុកការងាររដ្ឋបាល

២- លោក **ជួន តេច** ជាអធិការ ទទួលបន្ទុកការងាររដ្ឋបាល

៣- លោកស្រី **ចាន់ សុទ្ធាវី** ជាប្រធាននាយកដ្ឋានរដ្ឋប្បវេណី

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី

P.5

រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាម៉ីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែតុលា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ - កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៥១៧ អនក្រ-បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកព / ១០៩៥ / ០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អគ្គលេខាធិការ អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍ វិស័យបច្ចេកវិទ្យាគមនាគមន៍ ពត៌មានវិទ្យា

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **សេនា** ជូនលោក **Jie Woo Choi** ប្រធានក្រុមហ៊ុន **Open Net** នៃសាធារណរដ្ឋកូរ៉េ ដែលបានផ្តល់អំណោយ និង សហការយ៉ាងជិតស្និទ្ធ ក្នុងការជួយរៀបចំប្រព័ន្ធរដ្ឋបាល ពត៌មានវិទ្យា ទទួលបានលទ្ធផលល្អប្រសើរ គួរជាទីពេញចិត្ត ។

**មាត្រា ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អគ្គលេខាធិការ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍ វិស័យបច្ចេកវិទ្យា គមនាគមន៍ ពត៌មានវិទ្យា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២៨ ខែ ១០ ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា២
- រាជកិច្ច ✓
- ឯកសារ- កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៥១៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/រកម/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ

តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងផែនការ

## សំរេច

**មាត្រា ១ :** តែងតាំងលោក **សាង សម** ជាអធិការ នៃអគ្គាធិការដ្ឋាន ក្រសួងផែនការ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ. ថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០០២*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...៥១១៩...អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការលុបឈ្មោះមន្ត្រីរាជការចេញពីក្របខ័ណ្ឌរដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើ របស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សំរេច**

**មាត្រា ១ :** លុបឈ្មោះលោក **សោម ហាន** ចេញពីក្របខ័ណ្ឌមន្ត្រីរដ្ឋបាលស៊ីវិល នៃក្រសួងមហាផ្ទៃ ដោយមូលហេតុ ទទួលមរណភាព ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ អភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែ តុលា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចម្លងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣ "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៥៤៣០ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការផ្ទេរភារកិច្ច និងតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- តាមសំណើ របស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១** : ផ្ទេរភារកិច្ចលោក **ម៉ាស់ សារ៉េត** អភិបាលស្រុកគីរីវង់ អោយមកទទួលភារកិច្ចជាអភិបាលស្រុកព្រៃកប្បាស ។

**មាត្រា ២** : តែងតាំងលោក **តឹក តុងលីម** ជាអភិបាលស្រុកគីរីវង់ ខេត្តតាកែវ ។

**មាត្រា ៣** : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤** : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលខេត្តតាកែវ និងអស់លោក ដែលមានចែងក្នុងមាត្រា១ និង មាត្រា២ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

*រាជធានីភ្នំពេញ , ថ្ងៃទី២៩ ខែ តុលា ឆ្នាំ ២០០២*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចម្លងជូន** :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)*
- *ដូចមាត្រា ៤ (ដើម្បីអនុវត្ត)*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៥០.សសរ

## សេចក្តីសំរេច
## ស្តីពី
## ការបង្កើតគណៈកម្មការវាយតំលៃការដេញថ្លៃ
## ក្នុងការជ្រើសរើសក្រុមហ៊ុនគ្រប់គ្រងនាវាសញ្ចាតិកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ
- យោងតាមសេចក្តីត្រូវការចាំបាច់របស់រាជរដ្ឋាភិបាលក្នុងការជ្រើសរើសក្រុមហ៊ុនគ្រប់គ្រងនាវាសញ្ចាតិកម្ពុជា

## សំរេច

**ប្រការ១ :** បង្កើតគណៈកម្មការវាយតំលៃការដេញថ្លៃ ក្នុងការជ្រើសរើសក្រុមហ៊ុនគ្រប់គ្រងនាវាសញ្ចាតិកម្ពុជា។

| | | | | |
|---|---|---|---|---|
| ១- ឯកឧត្តម | **សេង** | **លីមនៅ** | អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២- ឯកឧត្តម | **ញាណ** | **ឡេង** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣- ឯកឧត្តម | **ឡេង** | **ធនយុទ្ធា** | អគ្គនាយកដឹកជញ្ជូននៃក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ៤- បណ្ឌិត | **ជា** | **ម៉ាន់ដេត** | ជំនួយការឯកឧត្តមទេសរដ្ឋមន្ត្រី សុខ អាន | សមាជិក |
| ៥- លោក | **ឃុយ** | **ហៀង** | អនុប្រធាននាយកដ្ឋានគមនាគមន៍ | សមាជិក |

**ប្រការ២ :** គណៈកម្មការមានភារកិច្ចពិនិត្យ ស្រាវជ្រាវ និងវាយតំលៃការដេញថ្លៃ ក្នុងការជ្រើសរើសក្រុមហ៊ុនដែលមានបទពិសោធន៍គួរអោយទុកចិត្ត និងមានសមត្ថភាព ក្នុងការងារគ្រប់គ្រងនាវាសញ្ចាតិកម្ពុជា។

**ប្រការ៣ :** ឯកឧត្តម អស់លោក ដូចមានឈ្មោះក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ អោយបានលទ្ធផលល្អ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០០២*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចំលងជូន :**
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៧-០២-២០៥ ប្រ.ក

# ប្រ កា ស

## ស្តីពី

## ការកែប្រែមណ្ឌលសិក្សាបច្ចេកទេសធនាគារទៅជា វិទ្យាស្ថានបច្ចេកទេសធនាគារ

-------

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០២/០៣៩ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីការតែងតាំងឯកឧត្តម **ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា ជាថ្មីម្តងទៀត
- បានឃើញប្រកាសលេខ ធ៨៩៨.៣៨៥ ប្រក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៨ ស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- បានឃើញប្រកាសលេខ ធ៨៩៩-១០២ ប្រក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ១៩៩៩ ស្តីពីរចនាសម្ព័ន្ធរបស់មណ្ឌលសិក្សាបច្ចេកទេសធនាគារ និង មុខងារ-ភារកិច្ចរបស់ការិយាល័យក្រោមឱវាទ
- យោងតាមភាពចាំបាច់និងសារៈសំខាន់នៃការបណ្តុះបណ្តាលវិស័យបច្ចេកទេសធនាគារ

## ស ំ រេ ច

**ប្រការ ១ :** មណ្ឌលសិក្សាបច្ចេកទេសធនាគារ ដែលបច្ចុប្បន្នជាអង្គភាពមួយស្មើថ្នាក់នាយកដ្ឋានរបស់ធនាគារជាតិនៃកម្ពុជា មានអាស័យដ្ឋានលេខ១៩អាបេ ផ្លូវលេខ១០២ សង្កាត់វត្តភ្នំ

ខ័ណ្ឌដូនពេញ ត្រូវបានកែប្រែឱ្យទៅជាបុគ្គលសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា ដែលមានរូបភាពគតិយុត្តិជាក្រុមហ៊ុនមានលក្ខណៈពាណិជ្ជកម្ម និងធ្វើសកម្មភាពក្រោមច្បាប់និងបទប្បញ្ញត្តិនានាដែលពាក់ព័ន្ធដូចជា ច្បាប់ពាណិជ្ជកម្ម និង ច្បាប់ពាក់ព័ន្ធនឹងការសិក្សាអប់រំជាដើម ។

**ប្រការ ២ :** មណ្ឌលសិក្សាបច្ចេកទេសធនាគារត្រូវប្តូរឈ្មោះជាផ្លូវការទៅជា **"វិទ្យាស្ថានបច្ចេកទេសធនាគារ"** និងជាភាសាអង់គ្លេស "Institute for Banking Studies" ។

**ប្រការ ៣ :** វិទ្យាស្ថានបច្ចេកទេសធនាគារត្រូវមានលក្ខន្តិកៈដោយឡែក ដែលក្នុងនោះត្រូវមានចែងអំពីរូបភាពគតិយុត្ត ដើមទុន ទីតាំង កម្មវត្ថុនៃការសិក្សាអប់រំ ភារកិច្ចនិងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល នាយកចាត់ការ រចនាសម្ព័ន្ធរបស់វិទ្យាស្ថាន និងការងារដទៃទៀតដែលពាក់ព័ន្ធ ។

**ប្រការ ៤ :** ដើមទុនដំបូងរបស់វិទ្យាស្ថានបច្ចេកទេសធនាគារមានចំនួន ១.០០០.០០០.០០០ រៀល (មួយពាន់លានរៀល) ដែលផ្តល់ដោយធនាគារជាតិនៃកម្ពុជា ក្នុងនាមជាភាគទុនិក ១០០ ភាគរយ ។ ដើមទុននេះនឹងត្រូវបង់ជា សាច់ប្រាក់និងជាសំភារៈតាមការជាក់ស្តែង ។

**ប្រការ ៥ :** វិទ្យាស្ថានបច្ចេកទេសធនាគារ ត្រូវធ្វើសកម្មភាពនិងមានការគ្រប់គ្រងដាច់ចេញពីធនាគារជាតិនៃកម្ពុជា និងត្រូវស្ថិតនៅក្រោមការដឹកនាំរបស់ក្រុមប្រឹក្សាភិបាលរបស់វិទ្យាស្ថាន ។

**ប្រការ ៦ :** ក្រុមប្រឹក្សាភិបាលរបស់វិទ្យាស្ថានត្រូវបានតែងតាំងដោយធនាគារជាតិនៃកម្ពុជា និងមានសមាជិកចំនួន ៥ រូប ។

**ប្រការ ៧ :** វិទ្យាស្ថានបច្ចេកទេសធនាគារត្រូវរៀបចំថវិកានិងផែនការហិរញ្ញប្បទាន ដើម្បីធានាឱ្យមានកិច្ចដំណើរការជាប្រក្រតីនិងមាននិរន្តរភាព ជាអាទិ៍ការយកថ្លៃសិក្សាតាមកំរិតមួយសមស្របដែលអាចធ្វើឱ្យមានតុល្យភាពរវាងចំណូលនិងចំណាយ ។

**ប្រការ ៨ :** កម្មវត្ថុចំបងនៃវិទ្យាស្ថានបច្ចេកទេសធនាគារ គឺផ្តល់សេវាអប់រំអំពីការងារធនាគារនិងបញ្ហាពាក់ព័ន្ធដទៃទៀត ដើម្បីលើកកំពស់មុខជំនាញបច្ចេកទេសធនាគារចំពោះមន្ត្រីបុគ្គលិក

ធនាគារជាតិនៃកម្ពុជា និងចំពោះសាធារណជន ។

**ប្រការ ៩ :** អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន-អង្គភាព ក្រោមឱវាទធនាគារជាតិនៃកម្ពុជាដែលមានការពាក់ព័ន្ធ និងវិទ្យាស្ថានបច្ចេកទេសធនាគារ ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ១០ :** រាល់ប្រកាស ឬលិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ១១ :** ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ថ្ងៃទី១៨ ខែ៧ ឆ្នាំ ២០០២

**ទេសាភិបាល**

**ជា ចាន់តូ**

**<u>កន្លែងទទួល :</u>**

- ដូចប្រការ ៩

" ដើម្បីអនុវត្ត "

- កាលប្បវត្តន៍
- ឯកសារ

**<u>ចម្លងជូន</u>**

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី

" ដើម្បីជូនជ្រាបជាពត៌មាន "

- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី

" ដើម្បីចុះផ្សាយក្នុងរាជកិច្ច "

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ......៣៥៣..........សសរ.កសក.បុ

# សេចក្តីសំរេច

## ស្តីអំពី

## ការចាត់តាំង និងប្តូរភារកិច្ចមន្ត្រីរាជការមួយចំនួន នៅក្នុងអង្គភាពគ្រប់គ្រងគំរោង នៃគំរោងបង្កើនផលិតភាពកសិកម្ម ក្នុងក្របខ័ណ្ឌឥណទានធនាគារពិភពលោក និងមូលនិធិអន្តរជាតិ សំរាប់អភិវឌ្ឍន៍កសិកម្ម

## រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញកិច្ចព្រមព្រៀងឥណទានអភិវឌ្ឍន៍នៃមូលនិធិអន្តរជាតិ លេខ ITF Cr N0110-KH ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ១៩៩៧ រវាងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារពិភពលោក
- បានឃើញកិច្ចព្រមព្រៀងឥណទានលេខ IFAD Ln No 423-KH ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៩៦ រវាងរាជរដ្ឋាភិបាលកម្ពុជា និងមូលនិធិអន្តរជាតិសំរាប់អភិវឌ្ឍន៍កសិកម្ម
- បានឃើញអនុស្សារណៈ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៩៧ រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញសេចក្តីសំរេចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ :
  - លេខ ៦៨៧ សសរ.កសក.បុ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០០ ស្តីពីការតែងតាំង និងប្តូរភារកិច្ចមន្ត្រីរាជការក្នុងសេចក្តីសំរេចលេខ ២១៧ សសរ.កសក ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ១៩៩៧, លេខ ២៤៩ សសរ.កសក ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ១៩៩៨ និងលេខ ០១២ សសរ.កសក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ១៩៩៩ ក្នុងអង្គភាពគ្រប់គ្រងគំរោង ដើម្បីអនុវត្តគំរោងបង្កើនផលិតភាពកសិកម្ម ក្នុងក្របខ័ណ្ឌឥណទានធនាគារពិភពលោក និងមូលនិធិអន្តរជាតិ សំរាប់អភិវឌ្ឍន៍កសិកម្ម ។
  - យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

# សម្រេច

**ប្រការ១ :** **ក- ចាត់តាំង**

១- ចាត់តាំង លោក **គ្រួយ គី** មន្ត្រីរាជការនាយកដ្ឋានផែនការ ស្ថិតិ និងសហប្រតិបត្តិការអន្តរជាតិ ជាលេខាធិការ ។

**ខ- ប្តូរភារកិច្ច**

១- ប្តូរភារកិច្ច លោកស្រី **ផ្លាំ ធីតា** បច្ចុប្បន្ន លេខាធិការនៃផែនការគណនេយ្យ និងហិរញ្ញវត្ថុ មកជាសមាជិកនៃកិច្ចការហិរញ្ញវត្ថុ និងត្រួតពិនិត្យ ។

២- ប្តូរភារកិច្ច កញ្ញា **មូល សុខារី** បច្ចុប្បន្ន លេខាធិការនៃប្រធានជំនាញការ មកជាសមភាគីនៃកិច្ចការគ្រប់គ្រងទ្រព្យសម្បត្តិ និងរបាយការណ៍ហិរញ្ញវត្ថុ របស់គំរោង ។

**ប្រការ២ :** មន្ត្រីរាជការដែលមានឈ្មោះនៅក្នុងប្រការ១ខាងលើ មានភារកិច្ចអនុវត្តការងាររបស់ខ្លួនស្របតាមខ្លឹមសារយោង (TOR) របស់បុគ្គលម្នាក់ៗ ដែលបានបញ្ជាក់នៅក្នុងផែនការការងាររបស់អង្គភាពគ្រប់គ្រងគំរោង។

**ប្រការ៣ :** អគ្គនាយកនៃក្រសួង អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានផែនការ ស្ថិតិ និងសហប្រតិបត្តិការអន្តរជាតិ ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស ប្រធាននាយកដ្ឋានជលផលអង្គភាពគ្រប់គ្រងគំរោង និងសាមីជនត្រូវអនុវត្តសេចក្តីសំរេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ភ្នំពេញ.ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០២

រដ្ឋមន្ត្រី

ចាន់ សារុន

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
  " ដើម្បីជូនជ្រាប "
- ដូចមានចែងក្នុងប្រការ ៣
  " ដើម្បីអនុវត្ត"
- ឯកសារ- កាលប្បវត្តិ